# អង់ហ្គោឡា

## សូចនាករប្រទេស

- **រយៈពេលមានជម្លោះនិងការប្រើប្រាស់គ្រាប់មីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមៈ** ប្រទេសអង់កូឡា មានមីន និង កាកសំណល់ពីសង្គ្រាមយ៉ាងសន្ធឹកសន្ធាប់ ។ ចំនួនគ្រាប់មីនត្រូវបានភាគីសង្គ្រាមប្រើយ៉ាងច្រើនចាប់តាំងពីសង្គ្រាមដើម្បី ឯករាជ្យនៅក្នុងឆ្នាំ ១៩៦១ រហូតមកដល់ចប់ជម្លោះនៅក្នុងឆ្នាំ ២០០២[១] ។
- **ការប៉ាន់ប្រមាណពីការប៉ះពាល់ៈ** យោងតាមការស្រាវជ្រាវពីផលប៉ះពាល់ដោយគ្រាប់មីនឆ្នាំ ២០០៧ (LIS) មានសហគមន៏ ៨ ភាគរយនៅគ្រប់ខេត្តទាំងអស់បានប៉ះពាល់ពីមីន និង កាកសំណល់ពីសង្គ្រាមដែលប៉ះពាល់ ប្រជាជន ២. ៤ លាននាក់ ។ ចំនួននេះអាចខ្ពស់ជាងដោយសារក្រុមស្រាវជ្រាវមិនអាចទៅដល់តំបន់មួយចំនួន[២] ។
- **សន្ទស្សន៏អភិវឌ្ឍធនធានមនុស្សៈ** ឈរលំដាប់ទី១៦២ ក្នុងចំណោម ១៧៩ ប្រទេស ការអភិវឌ្ឍន៏មនុស្សទាប (បើប្រៀបធៀបទៅនឹងប្រទេសលំដាប់ទី ១៦៦ នៃប្រទេស ១៧៧ នៅក្នុងឆ្នាំ ១២០០៤)[៣] ។
- **ចំណូលជាតិសរុប (តាមវិធីសាស្រ្ត អាទ្លូស)ៈ** ៣ ៤៥០ លានដុល្លា — លំដាប់ទី ១២០នៃប្រទេស ២១០ (ប្រៀបធៀបទៅនឹង ១១០៦ លានដុល្លា នៅក្នុងឆ្នាំ ២០០៤)[៤]
- **អាត្រាគ្មានការងារធ្វើៈ** គ្មានតួលេខ (ជាង៥០%គ្មាន និងក្រោមគ្មានការងារធ្វើ)[៥]
- **ធនធានខាងក្រៅសម្រាប់ថែទាំសុខភាព គិតជាភាគរយនៃចំណាយសរុបៈ** ៧%(ប្រៀបធៀបឆ្នាំ ២០០៤ មាន៩%)[៦]
- **ចំនួនអ្នកថែទាំសុខភាពអាជីពៈ** ១៥នាក់ក្នុងចំនួនប្រជាជន១០ ០០០ នាក់[៧]
- **ស្ថានភាពអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការៈ** មកទល់ថ្ងៃទី១ សីហា ឆ្នាំ ២០០៩ មិនមែនជាប្រទេសហត្ថលេខីទេ[៨]
- **ថវិកាចំណាយលើវិស័យពិការភាព :**មិនដឹង
- **ការវាស់វែងអំពីភាពក្រីក្រ និង ការអភិវឌ្ឍន៏ :** អង់ហ្គោឡាមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ដោយវិស័យប្រេង ដែលបានបណ្តាលអោយមានការស្ថាបនាឡើងវិញរីកដុះដាលក្រោយពីសង្គ្រាមបួនទសវត្សន៏មក ។ ទោះជាយ៉ាងណា មានអំពើពុករលួយខ្លាំង ហើយប្រជាជនភាគច្រើននៅតែរស់នៅត្រដាបត្រដួសប្រកបរបរកសិកម្ម ។ ប្រជាជនជិត ៧០%រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយអាយុកាលជាមធ្យមគឺតិចជាង៣៩ឆ្នាំឋិតនៅក្នុងចំណោមប្រទេស ដែលមានអាយុកាលទាបបំផុតនៅក្នុងពិភពលោក[៩] ។

## សេចក្តីសង្ខេបការជួយជនរងគ្រោះក្នុងប្រទេស

| ចំនួនសរុបនៃអ្នករងគ្រោះថ្នាក់ដោយសារមីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ចាប់ពីឆ្នាំ១៩៦១: មិនដឹង | | | | |
|---|---|---|---|---|
| ឆ្នាំ | ចំនួនសុរប | ស្លាប់ | របួស | មិនដឹង |
| ២០០៤ | ១៨៨ | ៧៣ | ១១៥ | 0 |
| ២០០៥ | ១០១ | ២៦ | ៧៥ | 0 |
| ២០០៦ | ១២១ | ១៩ | ១០២ | 0 |
| ២០០៧ | ៥៤ | ១៤ | ៣៨ | ២ |
| ២០០៨ | ៦៧ | ១២ | ៥៥ | 0 |
| សរុបរួម | **៥៣១** | **១៤៤** | **៣៨៥** | **២** |

- **ចំនួនប៉ាន់ស្មាននៃអ្នករស់រានពីគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមៈ**មិនដឹង ។ ការប៉ាន់ប្រមាណមិនអាចយកជាការបានមានរវាងពី ២៣០០០ និង ៨០០០០[១០] ។
- **ស្ថាប័នសម្របសម្រួល/ក្រុមបង្គោលជំនួយជនរងគ្រោះ**: ជាផ្លូវការគណកម្មការអន្តរវិស័យស្តីអំពីការដោះមីន និង ការជួយមនុស្សធម៌ សម្របសម្រួលជំនួយជនរងគ្រោះ (CNIDAH) ហើយ ក្រសួងសុខាភិបាល និង ជំនួយការសង្គម និង អនុវត្តសកម្មភាពសមាហរណកម្មពិការភាព ។ ប៉ុន្តែ CNIDAH មិនមានអំណាចឬមានសមត្ថភាពដើម្បីបញ្ជារក្រសួងពាក់ព័ន្ធឡើយ ។
- **ផែនការជួយជនរងគ្រោះ** ផែនការជាតិសម្រាប់សកម្មភាពសមាហរណកម្មស្តីអំពីជំនួយជនរងគ្រោះ ឆ្នាំ ២០០៧-២០១១ ត្រូវបានតាក់តែងឡើង តែភាគច្រើនមិនបានអនុវត្ត ។
- **សាវតារជំនួយជនរងគ្រោះ** នៅក្នុងឆ្នាំ២០០៥ អង្គការក្រៅរដ្ឋាភិបាលបានកត់សំគាល់ឃើញថា CNIDAH កាន់តែសកម្ម ក្នុងការចូលរួមក្នុងជំនួយជនរងគ្រោះ ហើយរដ្ឋាភិបាលបានសន្យាថា ការជួយជនរងគ្រោះកាន់តែខ្លាំងក្លាថែមទៀត[១១] ។" អង់កូឡាមានចំណូលពីប្រេងដ៏សំខាន់ដើម្បីវិនិយោគលើការសាងសង់ឡើងវិញ និង ការអភិវឌ្ឍន៏ ។ ហេតុដូចនេះហើយការជួយរបស់ម្ចាស់ជំនួយអន្តរជាតិសម្រាប់ជំនួយជនរងគ្រោះ និង ពិការភាពបានថយចុះជាយថាហេតុ ។

នៅពេលជម្លោះបញ្ចប់មានកំរោងគៀងគរ ការតាំងទីលំនៅជាថ្មី និង ការសាងសង់ឡើងវិញច្រើន តែពិការភាពមិនមែនជាគំរោងអាទិភាពទេ។ សេវាកម្មសង្គមនិង សុខាភិបាលរបស់រដ្ឋាភិបាលត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដោយសារជម្លោះរាប់ទសវត្សន៍ ហើយមកទល់ឆ្នាំ២០០៩ នៅតែមានកំរិតដដែល។ សេវាកម្មឯកជនមិនអាចទ្រទង់បានទេ សម្រាប់ជនរស់រានពីមីននិងកាកសំណល់ពីសង្គ្រាមភាគច្រើនបំផុតនោះ។ ហើយការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាលពីឆ្នាំ២០០៥-២០០៩ បានផ្តោតជាសំខាន់លើស្តារនីតិសម្បទា។ អវត្តមាននៃសេវាកម្មវិជ្ជការ តម្លៃដឹកជញ្ជូននិងសេវាផ្សេងៗ ជាឧបសគ្គយ៉ាងធ្ងន់ធ្ងរចំពោះអ្នករស់រាននិងជនពិការភាគច្រើនបំផុត។ តម្លៃមិនបានរួមបញ្ចូលដោយអ្នកផ្តល់សេវាទេ។ ការទទួលបានសេវាថែទាំសុខភាព ត្រូវបានលើកកំពស់ដោយសារការសាងសង់ឡើងវិញ ការធ្វើទំនើបកម្មបរិក្ខានិងការកែលំអបណ្តាញផ្លូវថ្នល់។ តែជារួមគឺនៅតែមានកំរិតដដែលជាពិសេសចំពោះអ្នកនៅតំបន់ជនបទនានា។ ការផ្តល់នូវការស្តារនីតិសម្បទាឡើងវិញបានថយចុះចាប់តាំងពីឆ្នាំ២០០៥មក ដោយការបរាជ័យនៃដំណើរការជាតូបនីយកម្មតាមវិស័យ ហើយនិងការចាកចេញរបស់អង្គការអន្តរជាតិទាំងអស់ដែលបានគាំទ្រនៅក្នុងឆ្នាំ២០០៩។ មកដល់ឆ្នាំ២០០៩ គ្មានមណ្ឌលណាមួយមានប្រតិបតិការពេញលេញដូចនៅក្នុងឆ្នាំ២០០៥ទេ។ បុគ្គលិកគ្មានប្រាក់ខែ ហើយគ្មានសម្ភារៈគ្រប់គ្រាន់។ ការគាំទ្រផ្លូវចិត្តនៅកំរិតសហគមន៍ ត្រូវបានផ្តល់ឡើងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង អង្គការជនពិការប៉ុណ្ណោះ ប៉ុន្តែមានករណីជាច្រើនបានទទួលរងការប៉ះទង្គិចដែលបណ្តាលមកពីការធ្លាក់ចុះនៃការគាំទ្រជាអន្តរជាតិ។ ដូចនៅក្នុងឆ្នាំ២០០៥ មិនមានរចនាសម្ព័ន្ធនៃការពិគ្រោះយោបល់ផ្លូវការទេ ហើយបុគ្គលិកក៏មិនបានទទួលការហ្វឹកហ្វឺនគ្រប់គ្រាន់ដែរ។ ឱកាសសមាហរណកម្មសេដ្ឋកិច្ចក៏មានកំរិតផងដែរ ដោយជារួមស្ថានភាពសេដ្ឋកិច្ចនៅលំបាក ហើយខ្វះការយល់ដឹងក្នុងចំណោមអ្នករស់រានអំពីសេវាដែលមានស្រាប់នានា។ ការផ្តួចផ្តើមភាគច្រើនបានចាប់ផ្តើមឡើង ដោយអង្គការក្រៅរដ្ឋាភិបាល បើទោះជាកម្មវិធីវិជ្ជាជីវៈ និងជំនួយសេដ្ឋកិច្ចរបស់រដ្ឋមានហើយក៏ដោយ។ មានច្បាប់ជាច្រើនចែងអំពីសិទ្ធិជនពិការ ប៉ុន្តែគ្មានមួយណាដែលទូលំទូលាយទេ ហើយមានពង្រាងច្បាប់ចាប់តាំងពីឆ្នាំ២០០០ ហើយរហូតមកដល់ឆ្នាំ២០០៩ ក៏នៅតែមិនទាន់អនុម័តដដែល។ ផែនការដើម្បីប្រមូលនិងវិភាគទិន្នន័យពីអ្នករស់រាននិងតម្រូវការរបស់គេជាប្រព័ន្ធមិនបានសំរេចគោលដៅហើយព័ត៌មានស្តីអំពីតម្រូវការ និងសេវាកម្មដែលគេទទួលបានក៏គ្មានដែរ[១២] ។

**ការទទួលជំនួយពីក្រុមអ្នកផ្តល់ជំនួយផ្សេងៗ**



## ភាពជឿនលឿនពីជំនួយជនរងគ្រោះនៅមូលដ្ឋាន

### *សាវតារអ្នកផ្តល់ចម្លើយ*

សម្រាប់អង់កូឡា ចម្លើយតបនឹងកម្រងសំណួរបានពីអ្នករស់រានពីមីននិងកាកសំណល់ពីសង្គ្រាម៣៥នាក់ ស្តីអំពីភាពជឿនលឿនលើជំនួយជនរងគ្រោះតាំងពីឆ្នាំ ២០០៥ត្រូវបានប្រើ[១៣] លើបុរស ២២ នាក់ ស្ត្រី ១០ នាក់ កុមារី២ នាក់ និង កុមារម្នាក់។ អ្នកផ្តល់ចម្លើយមានអាយុរវាង ១៥ ឆ្នាំ និង ៥៣ ឆ្នាំ ហើយពាក់កណ្តាលមាន អាយុរវាង ២៥ ឆ្នាំ និង ៤០ ឆ្នាំ។ ២ភាគ៣ ជាមេគ្រួសារ, ៣៤%នៃអ្នកឆ្លើយជាម្ចាស់ព្រទ្យសម្បត្តិ ហើយ២៣%បានបញ្ចប់មធ្យមសិក្សាឬខ្ពស់ជាង ហើយ ១៤%មិនបានទទួលការអប់រំជាផ្លូវការទេ។ អ្នកឆ្លើយជាច្រើននៅជានិស្សិតនៅពេលមានឧប្បត្តិហេតុកើតឡើង (១៣%ឬ១៧%) ហើយ៦%គ្មានការងារធ្វើ។ ក្រោយឧប្បត្តិហេតុភាពគ្មានការងារកើនដល់១៧%ដែលនៅទាបនៅឡើយបើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗ។ ទោះជាយ៉ាងណា មានអ្នកឆ្លើយ ១៤%បាននិយាយថា ចំណូលគ្រួសាររបស់គេគ្រប់គ្រាន់។

ក្រុមមនុស្សដ៏ច្រើន ៣៧% បានរស់នៅក្នុងទីក្រុងធំៗដោយមានសេវា ហើយ ៣១% បានរស់នៅរដ្ឋធានី លុនដា ហើយ ២៣% បានរស់នៅក្នុងភូមិនានាដោយសេវាកម្មមានកំរិត។ ក្រៅពីអ្នកផ្តល់ចម្លើយក្រុងលុនដា ក៏មានអ្នកផ្តល់ចម្លើយមកពី ខេត្ត ហួមបូ មូស៊ីកកូ បិងកើលឡា និង ខេត្ត ហួលឡាផងដែរ។ ដោយកង្វះទិន្នន័យ អំពីគ្រោះថ្នាក់យកជាការបានក្នុងរវាងឆ្នាំ ២០០៥ ដល់២០០៩ នោះ ជាហេតុមិនអាចកំណត់ថាតើអ្នកឆ្លើយត្រូវទៅនឹងសាវតារួមឬអត់។ ប៉ុន្តែសាវតារវាស៊ីគ្នាទៅនឹងការរកឃើញរបស់ LIS ដែលបានចង្អុលបង្ហាញ៦៨%នៃអ្នករងគ្រោះជាបុរស(៦៦% ក្នុងចំណោមអ្នកឆ្លើយ) ហើយភាគរយនៃអ្នករងគ្រោះជាស្ត្រីខ្ពស់ជាងជាមធ្យមភាគ នៅទូទាំងពិភពលោក។ តាមរបាយការណ៍ LIS ថា ៧៥%នៃអ្នករងគ្រោះមានអាយុចន្លោះ ១៥ ឆ្នាំ និង ៤៤ ឆ្នាំ ហើយភាគច្រើនត្រូវបានកត់ត្រាទុកនៅមូស៊ិកកូ[១៤]។

### *ការរកឃើញទូទៅ*

អ្នករស់រាន បានឃើញការកែលំអជាច្រើនក្នុងវិស័យមួយចំនួននៃការផ្តល់សេវាជំនួយការជនរងគ្រោះជាងផ្នែកផ្សេងៗ ហើយភាគច្រើននៅក្នុងការថែទាំសុខភាព។ សមាហរណកម្មសេដ្ឋកិច្ចត្រូវបានមើលឃើញថា ជាវិស័យអន់បំផុត។ សម្រាប់ការស្តារនីតិសម្បទា ចម្លើយរបស់អ្នករស់រានថា មានការខុសប្លែកខ្លាំងហើយមានលក្ខណវិជ្ជមាន ជាងចម្លើយអ្នកអនុវត្តន៍ជាក់ស្តែង។ ទោះជាយ៉ាងណាអ្នកឆ្លើយ៨០% មិនបានគិតថាគេបានទទួលសេវានៅក្នុងឆ្នាំ២០០៩ ច្រើនជាងឆ្នាំ២០០៥ទេ ហើយ ៦៦% ទៀតមិនបានគិតថា សេវាឥឡូវប្រសើរជាងមុននោះទេ។ អ្នកឆ្លើយមកពីទីក្រុងធំៗ បានឃើញថា មានការកែលំអគុណភាពច្រើនជាងនៅក្នុងរដ្ឋធានីឬនៅក្នុងភូមិនានា។ អ្នកនៅក្នុងរដ្ឋធានីបានឆ្លើយថាបរិមាណសេវាមានលក្ខណល្អប្រសើរជាងមុនបន្តិច។ អ្នកឆ្លើយ ៣៧% បានគិតថាសេវាសម្រាប់ស្ត្រី "យ៉ាប់បន្តិច" បើប្រៀបធៀបទៅនឹងសេវានានាដែលបុរសមាន។ ២៣% បានគិតថា សេវាសម្រាប់ស្ត្រីល្អប្រសើរ ហើយ ២០% បានគិតថា វាដូចតែគ្នាទេ។ ស្ត្រីបានឆ្លើយជាលក្ខណ បែបវិជ្ជមាន: ៥៨%បាននិយាយថា "យ៉ាប់បន្តិច"១៧%បាននយាយថា"ដូចគ្នា" ហើយ៨%បាននិយាយថា"គ្រាន់បើ"។ ជិតពាក់កណ្តាលនៃអ្នកឆ្លើយ(៤៦%) មិនបានច្បាស់ថាតើសេវាកម្មសម្រាប់កុមារអនុលោមទៅតាមអាយុរបស់គេ ហើយ ២០%បាននិយាយថា "មិនដែលទេ" ឬ ស្ទើរតែ "មិនដែល" ជាករណី។

ប្រជាជនភាគច្រើន (៧១%)បានត្រូវស្ទាបស្ទង់ដោយអង្គការក្រៅរដ្ឋាភិបាល ឬ រដ្ឋាភិបាលយ៉ាងហោចណាស់ ក៏មួយដងដែរក្នុងរយៈពេលប្រាំឆ្នាំកន្លងមក។ ជាងពាក់កណ្តាលនៃអ្នកឆ្លើយ (៥៤%)បាននិយាយថា ដោយសារការ ស្ទាបស្ទង់គេបានទទួលព័ត៌មានច្រើនអំពីសេវា។ ៣៧%បាននិយាយផងដែរថា គេបានទទួលសេវាច្រើនជាងមុន។ ២៣% មានអារម្មណ៍ចង់ស្តាប់

ហើយ ២០%បាននិយាយថា គេមានការលំបាកតិចតួចជាមួយការិយាធិបតេយ្យ។ ហើយអ្នករស់រាន ៤៦% បានមានឱកាសដើម្បីពន្យល់ពីសេចក្តីត្រូវការរបស់គេដល់រដ្ឋាភិបាល។ ចម្លើយទាំងនេះអាចទំនងជាវិជ្ជមានបន្តិច ដោយសារអ្នកឆ្លើយភាគច្រើនត្រូវបានទាក់ទងតាមរយៈបណ្តាញអង្គការជនពិការ ហើយតាមរយៈមជ្ឈមណ្ឌលស្តារនីតិសម្បទា នៅក្នុងតំបន់នានាដែលអាចទៅដល់។ ទោះជាយ៉ាងណាក៏ដោយ ចម្លើយបានបញ្ជាក់អះអាងពីការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករសកម្មភាព មីន អង្គការជនពិការក្នុងស្រុករហូតដល់ CNIDAH ក្នុងការប្រមូលជនរងគ្រោះ និង ព័ត៌មានពីអ្នករស់រាន។ បន្ថែមលើនេះ LIS និង CNIDAH បានចាប់ផ្តើមការស្ទង់មតិនៅក្នុងឆ្នាំ២០០៩ ហើយក៏បានគ្របដណ្តប់ផងដែរលើតំបន់គោលដៅដដែល។ ជាអកុសលព័ត៌មាននេះមិនមានឯកភាព មិនបានផ្ទៀងផ្ទាត់បញ្ជាក់ និងចងក្រងអោយប្រើទេ[១៥]។

**និន្នាការរួមនៃសេវាសម្រាប់អ្នករស់រានចាប់តាំងពីឆ្នាំ ២០០៥**




## *សង្គ្រោះបន្ទាន់និងការថែទាំបន្តផ្នែកវេជ្ជសាស្ត្រ*

ជាងពាក់កណ្តាលនៃអ្នកឆ្លើយ (៥៤%) បានឃើញថាការថែទាំសុខភាពបានត្រូវកែលំអចាប់តាំងពីឆ្នាំ ២០០៥ មកហើយ ៣១% បានគិតថាវានៅដដែលទេ។ ៣៧%បានគិតថាអ្នករស់រាន "ភាគច្រើនបំផុត" បានទទួលសេវាថែទាំសុខភាពតាមតម្រូវការរបស់គេហើយ ២០% បាននិយាយថា អ្នករស់រាន "មិនដែល " ឬ" ស្ទើរតែមិនដែល "បានទទួលការជួយតាមតម្រូវការទេ "។ ពីរភាគបីនៃអ្នកឆ្លើយបានគិតថា រដ្ឋាភិបាលបានបង្កើនការគាំទ្រ របស់ខ្លួនលើវិស័យសុខាភិបាល។ ជិត ៣ភាគ៤ បាននិយាយថា គេអាចបានទទួលសេវាថែទាំសុខភាពកាន់តែជិតផ្ទះ។ មនុស្សភាគច្រើនបានកត់សំគាល់ថា មានមណ្ឌលថែទាំសុខភាពច្រើនជាងមុន (៦៣%) និង ៧១% បាននិយាយាថា បរិក្ខារគ្រាន់បើជាងមុន។ អ្នកឆ្លើយមកពីទីក្រុងធំៗនិងរដ្ឋធានីមានលក្ខណៈ វិជ្ជមានជាងអ្នកឆ្លើយមកពីជនបទ។ យោងតាមអ្នកឆ្លើយទាំងអស់ផ្នែកដែលមានការកែលំអតិចតួចមាន : អ្នកធ្វើការសង្គ្រោះបឋម (៤០%)ងាយទទួលបានការបញ្ជូន(៣៧%)ក្រុមគ្រូពេទ្យ(២៩%) ហើយបានកែលំអរការដឹកជញ្ជូនគ្រាមានអាសន្ន(២៣%)។ ក្នុងចំណោមអ្នកអនុវត្តជាក់ស្តែង ៤០% បានឃើញការកែលំអ ប៉ុន្តែគេបានធ្វើការកត់សំគាល់ថា ការកែលំអមាននៅក្នុងផ្នែកដូចគ្នាជាមួយអ្នករស់រាន : បរិក្ខារល្អនិងប្រសើរច្រើន។ អ្នកអនុវត្តជាក់ស្តែងបានឃើញការជឿនលឿនតិចតួចនៅក្នុងកាទទួលបាន

ក្រុមពេញលេញការបញ្ជូន និង ការឆ្លើយតបបន្ទាន់។ ២៥%នៃ អ្នកអនុវត្តបានគិតថា មានការផ្គត់ផ្គង់ និង ការអោយថ្នាំច្រើន។ ហើយល្អបំផុតពួកគេបានឃើញថារដ្ឋាភិបាលបានរក្សាកិច្ចប្រឹងប្រែងរបស់ខ្លួន ប៉ុន្តែមិនបានបង្កើនវាទេ។ មួយចំនួនទៀតបានធ្វើការកត់សំគាល់ថាការកែលំអភាពលៃលកបានទិងលទ្ធភាពទទួលបានបានធ្វើអោយសម្រេចបានដោយប្រតិបត្តិករមិនមែនរដ្ឋាភិបាល។

លទ្ធផលខាងលើ គួរតែជាសេចក្តីថ្លែងអំណះអំណាងដោយរដ្ឋាភិបាលអង់កូឡាថា ទាំងអស់នៃផ្នែកជំនួយជនរងគ្រោះវិវឌ្ឍន៍យ៉ាងខ្លាំងនៅក្នុងផ្នែកការថែទាំដោយថ្នាំ តាមរយៈការសាងសង់បរិក្ខាថ្មី និង កែលំអរបស់មានស្រាប់[១៦]។ កត្តារួមចំណែកដ៏សំខាន់មួយគឺការកែលំអបណ្តាញផ្លូវ។ ទោះជាយ៉ាងណា ការចែកចាយបរិក្ខាមិនមានសមភាពទេនៅក្នុងទីក្រុង លុនដា និងទីក្រុងធំៗមួយចំនួនទៀត ដែលជាភស្តុតាងក្នុងការឆ្លើយតបខុសគ្នានៅខាងលើ។ ជាពិសេសការថែទាំសុខភាព នៅតំបន់ជនបទនៅតែមានកំរិតយ៉ាងខ្លាំង ហើយលទ្ធភាពទទួលបានត្រូវបានរារាំងដោយតម្លៃដឹកជញ្ជូនខ្ពស់។ សេវាកម្មសង្គ្រោះបន្ទាន់ តែងតែគ្មានបង់ប្រាក់ តែទទួលបានផលកម្រៃពីសន្តិសុខសង្គម ដើម្បីទទួលបានការបន្តការថែទាំដោយឥតគិតថ្លៃ ដែលប្រជាជនចាំបាច់ត្រូវតែបង់វិភាគទាន[១៧]។ វាក៏ត្រូវបានកត់សំគាល់ថា ជាឧបសគ្គចម្បងរបស់អង់កូឡានៅក្នុងឆ្នាំ២០០៩ គឺ ប្រសិទ្ធិភាពជាក់ស្តែងនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលបានកែលំអ កង្វះបុគ្គលិកមានគុណសម្បត្តិនិងការផ្គត់ផ្គង់ ត្រូវបានលើកដោះស្រាយជាជាងការងារហេដ្ឋារចនាសម្ព័ន្ធ និង រាយការណ៍បន្ត។

***ការស្តារនីតិសម្បទា***

អ្នកឆ្លើយ ៤៣% បាននិយាយថា ការស្តារនីតិសម្បទានៅដដែលចាប់តាំងពីឆ្នាំ២០០៥មក ហើយ២៩%បានឃើញមានការកែលំអ និង ១៤% បានឃើញថា ចុះអន់ថយ[១៨]។ ហើយ ២៩%បាននិយាយថា អ្នករស់រាន "ជួនកាល" គ្រាន់តែបានទទួលស្តារនីតិសម្បទាដែលគេត្រូវការ ហើយ ២៦% បានគិតថា សេវាទាំងនេះ "មិនដែល" ឬ "ស្ទើរតែមិនដែល" ទទួលបាន និង ២០% បាននិយាយថា "ភាគច្រើនបំផុត" ឬ "តែងតែ"។ នៅ លុនដា និង ហួមបូ ការឆ្លើយតបវិជ្ជមានមានភាគច្រើនជាងកន្លែងផ្សេង។ ប្រជាជនបានឃើញការជឿនលឿនទៅមុខច្រើនក្នុងការទទួលសេវាកម្មបាន(៨០%) ការជួសជុលមិនបង់ថ្លៃ (៦៦%) ហើយបុគ្គលិកបានទទួលការហ្វឹកហ្វឺនល្អ (៦០%)។ តែមាន ៣% បានគិតថា មានមណ្ឌលច្រើន ឯ ១៤% បាននិយាយថា គេបានទទួលសេវាកាន់តែជិតផ្ទះ និង ២៣% បានឃើញថា កាន់តែងាយស្រួលទទួលការបញ្ជូនរកសេវា។ គ្មានអ្នកអនុវត្តណាបានឃើញការកែលំអនៅក្នុងការស្តាសម្បទាទេ ហើយ៤០% បានឃើញភាពយ៉ាប់យឺនឡើង។ គេក៏បានមានចំណុចអវិជ្ជមានចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល។ សូចនាករពីភាពជឿនលឿនទាក់ទងនឹងការបង្កើតមណ្ឌលច្រើនឡើង ហេដ្ឋារចនាសម្ព័ន្ធប្រសើរឡើង គុណភាពល្អឡើង ហើយការផ្គូឧបករណ៍ ជំនួយដោយមិនបង់ប្រាក់ បង្កើនលទ្ធភាពទទួលបាន។ អ្នកអនុវត្តទាំងអស់បានឆ្លើយថា រដ្ឋាភិបាល "មិនបានធ្វើអ្វីទេ" ឬ "បានកាត់បន្ថយកិច្ចប្រឹងប្រែងរបស់ខ្លួន"។

ជាបឋម ការមើលឃើញលទ្ធផលផ្ទុយគ្នានេះអាចត្រូវបានពន្យល់ដោយការយល់ឃើញផ្សេងៗ រវាងអ្នកទទួលសេវា និងអ្នកផ្តល់សេវាគាំទ្រការស្តារនីតិសម្បទា។ ចន្លោះឆ្នាំ ២០០៥ និង ២០០៩ វិស័យស្តារនីតិសម្បទាបានពឹងផ្អែកយ៉ាងខ្លាំងទៅលើការគាំទ្រពីអង្គការអន្តរជាតិ និង កាកបាទក្រហមអន្តរជាតិ។ នៅក្នុងឆ្នាំ ២០០៥ អង្គការទាំងនេះ បានធានាអោយមានសម្ភារៈការគាំទ្រការគ្រប់គ្រងការហ្វឹកហ្វឺនបុគ្គលិក ផ្តល់ប្រាក់ខែ និង សោហ៊ុយធ្វើដំណើរ អ្នកជំងឺគាំទ្រទៅលើកម្មវិធីថ្នាក់ជាតិគ្រប់គ្រងដោយរដ្ឋាភិបាលសម្រាប់ស្តារនីតិសម្បទា និង វិញ្ញាណ (PNR)។ ក្រសួងសុខាភិបាល (MoH) នៅឆ្នាំ ២០០១ បានចាប់ផ្តើមនិងមានបំណងផ្តល់ស្តារនីតិសម្បទាយ៉ាងទូលំទូលាយដល់ជនពិការដោយការបង្កើតអោយមាននិរន្តភាពនៃសមត្ថភាពថ្នាក់ជាតិ។ PNR បានត្រូវកំណត់អោយបញ្ចប់នៅក្នុងឆ្នាំ ២០០៥ តែត្រូវបានបន្តជាច្រើនដង(ហើយថ្មីៗនេះរហូតដល់ឆ្នាំ២០១០) ដោយសារ

សមត្ថភាពថ្នាក់ជាតិនៅមិនទាន់គ្រប់គ្រាន់ បើទោះណាជាមានការបន្តគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីអន្តរជាតិក្តី។ ទោះជាយ៉ាងណាក៏ដោយ ជាផ្នែកមួយនៃដំណើរការជាតូបនីយកម្ម ប្រតិបត្តិករ បានកត់បន្ថយការគាំទ្របន្តិចម្តងៗ ក្នុងចន្លោះឆ្នាំ ២០០៥ និង២០០៩ ដោយអ្នកប្រតិបត្តិករចុងក្រោយចាកចេញនៅខែសីហា ឆ្នាំ ២០០៨។ ការគាំទ្រហិរញ្ញវត្ថុត្រូវបានបញ្ចប់ ដោយសារក្រសួងសុខាភិបាលមិនមានលទ្ធភាពរៀបចំសំណើរសុំបន្តរការគាំទ្រទាន់ពេល។ នៅពេលដែលការគាំទ្រជាអន្តរជាតិចប់ភ្លាមសមត្ថភាពនៃដំណើរការមណ្ឌលបានធ្លាក់ចុះ ដោយខ្វះខាត សម្ភារៈ បុគ្គលិកគ្មានប្រាក់ខែ ហើយចំនួនអ្នកជំងឺថយចុះដោយសារមិនមានថ្លៃធ្វើដំណើរ[១៩]។ អ្នកអនុវត្តម្នាក់ បាននិយាយថា" បើទោះជានៅមានសេវាមិនបង់ប្រាក់ក៏ដោយ ឥឡូវអ្នកជំងឺគ្មានលទ្ធភាពមក ហើយបុគ្គលិកក៏អញ្ចឹងដែរ ជាបច្ចេកទេសពួកគេគ្មានការងារដោយសារខ្វះខាតសម្ភារៈ ឬ"គ្មានអ្នកជំងឺ"។

កង្វះឆន្ទៈនយោបាយ និង ការមិនចូលរួមរបស់ក្រសួងសុខាភិបាល ត្រូវបានលើកឡើងជាញឹកញាប់ដោយបុគ្គលិកស្តារ និងអង្គការគាំពារការស្តារនីតិសម្បទា ដែលនាំអោយបរាជ័យដល់និរន្តរភាព PNR ។ អ្នកអនុវត្តម្នាក់ បានធ្វើការកត់សំគាល់ថា អង្គការនានាបានដកចេញពីវិស័យនេះ ដោយមិនបានធ្វើអោយមានជំរើសនិរន្តរភាពពិតប្រាកដនៅនឹងកន្លែងទេ។ នៅក្នុងខែឧសភា ឆ្នាំ ២០០៥ រដ្ឋាភិបាលបានទទួលស្គាល់ថា នឹងបន្តកិច្ចខំប្រឹងប្រែងរបស់ខ្លួន ដើម្បីអោយមាននិរន្តភាពសេវាដោយការផ្គត់ផ្គង់បុគ្គលិក និង បរិក្ខារតែស្តារនីតិសម្បទាជាវិស័យដែលមានភាពជឿនលឿនតិចបំផុត[២០]។

ទោះជាយ៉ាងណា ការឆ្លើយតបរបស់អ្នករស់រានមានភាពវិជ្ជមានច្រើន ជាពិសេសលើ ការលៃអោយទទួលបាន និងការហ្វឹកហ្វឺនបុគ្គលិក ដែលនេះជាផ្នែកមានភាពជឿនលឿន។ ជាដំបូង អង្គការបានរ៉ាប់រងលើតម្លៃ និង សេវា ដែលនៅតែគ្មានបង់ប្រាក់នៅពេលដែលមណ្ឌលក្លាយជារបស់ជាតិ។ ក្នុងកំឡុងឆ្នាំ ២០០៥ និង ២០០៩ អង់កូឡា បានវិនិយោគក្នុងការហ្វឹកហ្វឺនមិនថាតាមរយៈការគាំទ្រពីអង្គការអន្តរជាតិ ឬ ដោយការជួយអ្នកបច្ចេកទេសអោយ ទៅរៀននៅក្រៅប្រទេស ឬតាមរយៈការឆ្លើយឆ្លងនោះទេ។ អ្នករស់រានមួយចំនួនប្រហែលជាមិនបានធ្វើការកត់ សំគាល់ពីការផ្លាស់ប្តូរទេ ពីព្រោះវាកើតឡើងថ្មីៗពេក។ ហើយនេះអាចពន្យល់ពីការឆ្លើយតបវិជ្ជមានច្រើននៅ លុនដា និង ហួមបូ ជាកន្លែងដែលអង្គការអន្តរជាតិបានបញ្ឈប់នៅក្នុងខែកក្កដា ឆ្នាំ ២០០៨។ បញ្ហាការគ្រប់គ្រង ដូចជា ប្រាក់ខែបុគ្គលិក ប្រហែលជាគេមិនបានធ្វើការកត់សំគាល់ផងដែរ។ កន្លែងដែលអ្នករស់រានបានធ្វើការកត់សំគាល់ថា មានភាពជឿនលឿនតិចតួច (ចំនួន និង ភាពប្រហែលនៃសេវា) គ្មានកិច្ចខិតខំប្រឹងប្រែងពីរដ្ឋាភិបាលក៏ត្រូវបាន រាយការណ៍ថាៈ គ្មានការបង្កើតមណ្ឌលថ្មី ហើយ មណ្ឌលភាគច្រើននៅក្នុងទីរួម ខេត្តគ្មានយន្តការសម្រួលអោយទៅ បាននៅក្នុងឆ្នាំ ២០០៥-២០០៩។ នេះក៏អាចជាការពន្យល់នូវចម្លើយវិជ្ជមានពីអ្នករស់នៅ ក្នុងទីក្រុងធំៗនៃហួមបូ និង លុនដាផងដែរ។

### ***ការគាំទ្រផ្លូវចិត្ត និង សមាហរណកម្មសង្គម***

អ្នកឆ្លើយ ៣៤%បាននិយាយថា សេវាគាំពាផ្លូវចិត្ត និង សមាហរណកម្មសង្គមបានកែលំអតាំងពីឆ្នាំ ២០០៥ ហើយចំនួនប្រជាជនដូចគ្នាបានគិតថា មិនមានការផ្លាស់ប្តូរអ្វីទេ។ ៣ភាគ៤ បាននិយាយថាអ្នករស់រាន "ភាគច្រើនបំផុត" បានទទួលសេវាដែលគេត្រូវការ ហើយ ៣៧%បាននិយាយថា "មិនដែល" ឬ " ស្ទើរតែជាករណីមិនដែលសោះ"។ អ្នករស់រាន (៦០%)មានអារម្មណ៍ថា មានសិទ្ធិអំណាច ហើយ ៤២% បានគិតថា អ្នករស់រានគិតថាជា "ករណី សម្បុរសធម៌"កាន់តែតិចឡើង។ ចន្លោះ ៣០% និង៣៥%បានគិតថា មានសេវាកម្មច្រើន ហើយគុណភាពក៏បាន កែលំអដែរ និងមានអ្នកធ្វើការសង្គមច្រើនឡើង។ ២០% បានគិតថា រដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់សកម្មភាពផ្លូវចិត្ត ឬ មានក្រុមគាំទ្រមិត្តច្រើនត្រូវបានបង្កើតឡើង។ អ្នកអនុវត្តទាំងអស់បានគិតថា សេវាកម្មផ្លូវចិត្តនៅតែដដែល ហើយរដ្ឋាភិបាលមិនបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទេ។

ក្នុងកំឡុងឆ្នាំ ២០០៥-២០០៩ រដ្ឋាភិបាលបានរាយការណ៍ថា ខ្លួនពឹងផ្អែកយ៉ាងខ្លាំងទៅលើអង្គការជាតិ និង អង្គការជនពិការសម្រាប់ការគាំទ្រសេវាកម្មផ្លូវចិត្តនៅក៏រិតសហគមន៏ តែគ្មានរចនាសម្ព័ន្ធពិគ្រោះយោបល់ជាផ្លូវការ ហើយខ្វះបុគ្គលិកដែលបានទទួលការហ្វឹកហ្វឺន[២១] ។ ការគាំទ្រផ្លូវចិត្តគួរតែត្រូវរួមបញ្ចូលនៅក្នុង PNR តែវាមិនដែលកើតឡើងទេ។ អ្នកឆ្លើយភាគច្រើននៅក្នុងការស្ទង់មតិនេះ ត្រូវបានទាក់ទងតាមរយៈបណ្តាញអង្គការជនពិការ ដែលអាចមានលើចំលើយរបស់គេ។

អ្នករស់រានមួយចំនួនបានលើកឡើងពីការទទួលការជួយជំនួយនេះតាមរយៈក្រុមគ្រួសាររបស់គេ និងយោធិនដែលរស់រាន (៧%) បានឆ្លើយវិជ្ជមាន។ តែអ្នករស់រានជារួមបានឆ្លើយបញ្ជាក់ថា ខ្វះការប្រឹក្សាយោបល់ជាផ្លូវការនិងក្រុមគាំទ្រមិត្ត។ អ្នកអនុវត្តម្នាក់បានធ្វើការតក់សំគាល់ថា "គ្មានអ្នកចិត្តវិទ្យានៅក្នុងមណ្ឌលស្តារនីតិសម្បទានានាទេ។ មានកម្មវិធីខ្លះគាំទ្រដល់អ្នករស់រាន តែគេផ្តោតលើទាហានចាស់និងអង្គការជនពិការទេ ហើយបើទោះជាមានវត្តមានកាន់តែច្រើននៃសេវាក៏នៅតែខ្វះមធ្យោបាយជាប្រព័ន្ធក្នុងការអនុវត្តការគាំទ្រផ្លូវចិត្តដែរ" ។

**ការបំពេញតម្រូវការរបស់អ្នករស់រានចាប់តាំងពីឆ្នាំ ២០០៥ មក**




## ***សមាហរណកម្មសេដ្ឋកិច្ចៈ***

ចម្លើយតបអវិជ្ជមានបំផុត គឺវិស័យសមាហរណកម្មសេដ្ឋកិច្ចៈ ២៩%បានគិតថា សេវាកម្មជារួមមានការយ៉ាប់យឺនឡើង ហើយ ២៩% បានគិតថា វានៅតែដដែលដូចឆ្នាំ ២០០៥ ទេ។ ចំនួនអ្នកឆ្លើយក្រុមធំបំផុត (៣១%) បាននិយាយថា អ្នករស់រាន " មិនដែល " ឬ "ស្ទើរតែមិនដែល "ទទួលជំនួយសមាហរណកម្មសេដ្ឋកិច្ចដែលគេត្រូវការ នោះទេ តែ ២៣%ថា " ជូនកាល"បាន ហើយ ៦% បាននិយាយថា " ស្ទើរតែ " ឬ "តែងតែ"[២២] ។ ៨៤%នៃអ្នកឆ្លើយ សំណួរទាំងនោះ បានគិតថា ភាពគ្មានការងារធ្វើខ្ពស់ដែលអ្នករស់រានជាជំរើសចុងក្រោយដែលត្រូវជ្រើសរើសអោយ ធ្វើការងារ[២៣] ។ អ្នករស់រានបាន មើលឃើញភាពជឿនលឿនទៅមុខច្រើននៅក្នុងកំណើនឱកាសទទួលបានការហ្វឹកហ្វឺនវិជ្ជាជីវៈ(៦០%) ការអប់រំនិងទទួលសេវាជិតផ្ទះ(៥៧%តាមផ្នែកមួយៗ) ។ ហើយគេបានឃើញការកែលំ អតិចតួចលើឱកាសទទួលបានការងារ (២៩%) កំណើនសោធននិវត្តន៏ (២៦%) ហើយនិងការដាក់អោយធ្វើការ(២៣%) និង ការថយចុះនៃការរើសអើងនៅក្នុងវិស័យការងារនិងការអប់រំ(២០%) ឬ ការអនុវវត្តន៏អោយកាន់តែប្រសើរនូវកូតាងារងារ(១១%)។ ៤០% ក្នុងចំណោមអ្នកអនុវត្តន៏បានមើលឃើញភាពជឿនលឿននៅក្នុងឱកាសធ្វើសមាហរណកម្មសេដ្ឋកិច្ចភាគច្រើនបំផុតកំណើនទទួលបានការអប់រំ និងការហ្វឹកហ្វឺនវិជ្ជាជីវៈ។ ដូចអ្នករស់រាន គេបានធ្វើការកត់សំគាល់ភាព

ជឿនលឿនតិចតួចបំផុតនៅក្នុងឱកាសទទួលបានការងារ និង ការដាក់អោយធ្វើការងារ ។

អង្គការជាច្រើន និង រដ្ឋាភិបាលបានអនុវត្តសកម្មភាពសមាហរណកម្មសេដ្ឋកិច្ចដែលមានស្រាប់ ។ នៅក្នុងឆ្នាំ ២០០៥-២០០៩ បានប្រតិបត្តិការមជ្ឈមណ្ឌលហ្វឹកហ្វឺនវិជ្ជាជីវៈជាច្រើន ប៉ុន្តែការទទួលបានរបស់អ្នករស់រាននៅមានកំរិត ដោយសារតែគេមិនបានដឹងពីវត្តមានរបស់វា ។ ចាប់តាំងពីឆ្នាំ២០០៥ រដ្ឋាភិបាលបានចាប់ផ្តើមផ្តោតលើការ បង្កើតសហករណ៍រកប្រាក់ចំណូលនៅសហគមន៍ ដែលជាវិធីសាស្រ្តយកពីអង្គការ ។ ទោះជាយ៉ាងណា ជាគោលការណ៍ការផ្តួចផ្តើមរបស់រដ្ឋាភិបាលភាគច្រើនផ្តោតលើទាហានចាស់ ។ ហើយអង្គការអន្តរជាតិមួយចំនួនបានបន្ថយសកម្មភាពសមាហរណកម្មសេដ្ឋកិច្ចរបស់គេនៅក្នុងឆ្នាំ២០០៥[២៤] ។ អង្គការជនពិការ និង អង្គការក្នុងស្រុកបានទទួលសមត្ថភាព ច្រើនក្នុងវិស័យនេះ (ជារឿយៗដោយមានការគាំទ្រពីអន្តរជាតិ) ។ ប៉ុន្តែអត្រាអត់ការងារធ្វើខ្ពស់ចំនួនជនពិការដែលគ្រប់អាយុត្រូវធ្វើការច្រើន អត្រាអនក្ខភាពពួកគេខ្ពស់ ហើយផ្តោតតែនៅតំបន់ជាយក្រុងត្រូវបានមើលឃើញថាជាឧបសគ្គយ៉ាងធ្ងន់ធ្ងរនៅក្នុងឆ្នាំ២០០៥-២០០៩ ។ មានសេវាតិចតួចណាស់ដែលអាចរកបាននៅជនបទជាជាងនៅក្នុងតំបន់ជាយក្រុងនោះ[២៥] ។

## *ច្បាប់ និង គោលនយោបាយសាធារណៈ*

ចំនួនពាក់កណ្តាលនៃអ្នករស់រានបានគិតថាការការពារសិទ្ធិបានធ្លាក់ចុះ ឬ បានប្រសើរឡើង (២៥%ម្ខាង) ហើយ ២៣% មិនបានឃើញការផ្លាស់ប្តូរទេ ។ ច្រើនជាងពាក់កណ្តាល (៥១%) បានឃើញថា សិទ្ធិអ្នករសរាន "មិនដែល" ឬ "ស្ទើរតែ មិនដែល "ត្រូវបានបំពេញទេ ។ អ្នករស់រានបានកត់សំគាល់ថា មានភាពជឿនលឿនខ្លាំងនៅក្នុង ការបង្កើនការយល់ដឹង នៅក្នុង ចំណោមសាធរណជនទូទៅ អំពីសិទ្ធិជនពិការ (៥៧%) ។ ប៉ុន្តែចំនួនតិចជាងបានកត់ សំគាល់ថា គោលនយោបាយ និង ច្បាប់ថ្មីៗទាក់ទងទៅនឹងអ្នករស់រានត្រូវបានបង្កើតឡើង(២៣%) ហើយច្បាប់ត្រូវបានអនុវត្តច្រើន (២៦%) ឬ ថាគេបានបង្កើនធនធានសម្រាប់វិធានការផ្លូវច្បាប់ នៅពេលដែលសិទ្ធិរបស់គេត្រូវបានរំលោភបំពាន (២៥%) ។ អ្នកអនុវត្តច្រើនបំផុត (៦០%)បានគិតថាការការពារសិទ្ធិរបស់អ្នករស់រាននៅតែ ដដែលទេ ។

ច្បាប់ និងក្រិត្យនានាទាក់ទងជាមួយពិការភាពបានកើតមានតែចំណេះដឹងអំពីច្បាប់នៅទាប ហើយគ្មានវិធានអនុវត្តត្រូវបានបង្កើតឡើងសម្រាប់ពួកគេខ្លះនោះទេ ។ ច្បាប់ផ្សេងៗផ្តល់ការការពារដល់ក្រុមជនពិការ តែមិនបានរួមបញ្ចូលពិការផ្សេងទៀតទេ ។ ច្បាប់មិនបានត្រូវអង្កេតតាមដានទេ[២៦] ហើយនៅក្នុងឆ្នាំ២០០៥ សន្និសិទ្ធនៃអ្នកជំនាញ CNIDAH បានកត់សំគាល់ថាបើទោះជាមានច្បាប់ក៏ដោយ ក៏មិនបានអនុវត្តដែរ[២៧] ។ ហើយគ្មានការផ្លាស់ប្តូរទេនៅក្នុងឆ្នាំ២០០៩ ហើយពង្រាងច្បាប់ពិការភាពទូលំទូលាយបានកើតឡើងតាំងតែពីឆ្នាំ២០០០មក ។ នៅចុងឆ្នាំ២០០៨ និតិវិធីដើម្បីអនុមតិពង្រាងច្បាប់ត្រូវបានចាប់ផ្តើម តែគ្មានភាពជឿនលឿនទៅមុខត្រូវបានរាយការណ៍មកទេ ។ អ្នកអនុវត្តម្នាក់បាននិយាយថា ការផ្តល់យោបល់លើច្បាប់និងគោលនយោបាយសាធារណៈ " រដ្ឋាភិបាលមិនបានធ្វើអ្វីទេ ហើយនៅតែមិនធ្វើអ្វីដដែល ។ អ្វីក៏ដោយដែលជឿនលឿនទៅមុខដោយសារតែការងារអង្គការជនពិការប៉ុណ្ណោះ" ។

នៅពេលសួរអោយឆ្លើយទៅនឹងលទ្ធផលបឋមនៃការស្ទង់មតិ តំណាង CNIDAH បានប៉ាន់ប្រមាណយ៉ាងត្រឹម ត្រូវថាគេអាចរកឃើញភាពប្រសើរឡើងមួយចំនួន ។ តំណាងបានកត់សំគាល់ថា ភាពជឿនលឿនបានធ្វើឡើងនៅក្នុងការថែទាំសុខភាព ហើយការគាំទ្រផ្លូវចិត្តមានកំរិតយ៉ាងខ្លាំង នៅកំរិតសហគមន៍ ហើយរដ្ឋាភិបាលបានបង្កើនកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយវិស័យឯកជនដើម្បីបង្កើនឱកាសរកការងារ ។ គាត់បានបន្ថែមថា ច្បាប់នៅមានចំនុចខ្សោយច្រើនណាស់ ជាពិសេសពាក់ព័ន្ធនឹងកូតា

ទទួលបានការងារ។ គាត់បានបន្ថែមទៀតថា សេវាកម្មមិនបានកែលំអទេ តែការផ្លាស់ប្តូររបស់អ្នករស់រានក៏មិនជាជុំកំភួនដែរ ដោយធ្លាប់រងការលំបាកមកជាយូរ ហើយនិងក៏លើកយោបល់ផងដែរថា អង្គការអន្តរជាតិមិនបានអនុវត្តនូវរយៈពេលសមស្រប គ្រប់គ្រាន់ក្នុងការផ្ទេរ អោយនោះទេ។

## ការសម្រេចបានដំណើរការជួយជនរងគ្រោះ

| ឆ្នាំ | ទម្រង់ J និយាយពីការជួយដល់ជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅ ឯកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ ស្តីពីការជួយជនរងគ្រោះ | សេចក្តីថ្លែងការណ៍នៅ ឯកិច្ចប្រជុំរដ្ឋភាគីស្តីពីការជួយជនរងគ្រោះ | អ្នកជំនាញផ្នែកជំនួយជនរងគ្រោះ | អ្នករស់រានជីវិតពីមីនជាគណៈប្រតិភូ |
|---|---|---|---|---|---|
| ២០០៥ | គ្មាន | មាន | គ្មាន | មាន | គ្មាន |
| ២០០៦ | មាន | មាន | មាន | មាន | គ្មាន |
| ២០០៧ | គ្មាន | មាន | មាន | មាន | គ្មាន |
| ២០០៨ | គ្មាន | មាន | មាន | មាន | គ្មាន |
| ២០០៩ | គ្មាន | មាន | មិនដឹង | មាន | គ្មាន |

នៅក្នុងឆ្នាំ ២០០៥ CNIDAH បាននិយាយថា ខ្លួនមានការ " ព្រួយបារម្ភយ៉ាងខ្លាំង " អំពីស្ថានភាពនៃអ្នករស់រានពីគ្រាប់មីន និងកាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ហើយខ្លួនបានចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងលើអ្នករស់រានអំពីមីន និង ជនពិការផ្សេងៗទៀត តែខ្លួនមិនមានលទ្ធភាពអនុវត្ត " ការងារដ៏មហិមានេះទេ " បើគ្មានការជួយទេ នោះ[២៨]។ នៅក្នុងឆ្នាំ ២០០៥ នេះដែរ ខ្លួនក៏បាននិយាយថា រដ្ឋាភិបាលបានសន្យាជួយគាំទ្រហិរញ្ញវត្ថុច្រើនថែមទៀត ដល់ជំនួយជនរងគ្រោះ ហើយអង្គការបានយល់ថា CNIDAH ក្លាយជាសកម្មខ្លាំងឡើងលើបញ្ហានេះ។ ទោះជាយ៉ាងណា ដោយមានការធ្លាក់ចុះជាបន្តបន្ទាប់នូវការគាំទ្រជាអន្តរជាតិ ការប្រកួតជាមួយអាទិភាពជាតិ កង្វះនូវសមត្ថភាព និង ការសម្របសម្រួលនោះ សញ្ញាវិជ្ជមានឆ្នាំ២០០៥ មិនបានឃើញរហូតដល់សព្វថ្ងៃ។

ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង២៦ ដែលមានចំនួនអ្នករស់រានដ៏ច្រើនសន្ធឹក ហេតុដូច្នេះហើយក៏ជាឱកាសដ៏អស្ចារ្យតែក៏មានតម្រូវការនិងសេចក្តីរំពឹងទុកដ៏មហិមាសម្រាប់ជំនួយដែល CNIDAH បានរំពឹងទុកថានឹងមាននិរន្តរភាពនៃការគាំទ្រ បច្ចេកទេសដើម្បីធ្វើផែនការ និង បង្កើនកិច្ចសម្របសម្រួល។ នេះជាចំណុចខ្សោយពីរដែលបានរកឃើញនៅក្នុងឆ្នាំ២០០៤។ ហើយចំណុចខ្សោយផ្សេងៗទៀត ការទទួលបានសេវានៅមានកំរិតនិងកង្វះព័ត៌មានអំពីចំនួន និង តម្រូវការរបស់អ្នករស់រានពីគ្រាប់មីន[២៩]។

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តដើម្បីអនុវត្តផែនការសកម្មភាពទីក្រុងណៃរ៉ូប៊ី អង់កូឡាបានបង្ហាញទិសដៅរបស់ខ្លួន នៅក្នុងខែវិច្ឆិកាឆ្នាំ ២០០៥ តែទិសដៅទាំងនោះមិនឆ្លាតទេ។ ទិសដៅទាំងនោះត្រូវបានកែឡើងវិញ និង ផែនការ (ផែនការសមាហរណកម្មសកម្មភាពជាតិស្តីពីជំនួយជនរងគ្រោះឆ្នាំ២០០៧-២០១១) ត្រូវបានបង្កើតឡើងតែមិនដែលបង្ហាញជាផ្លូវការទេ[៣០]។ គោលបំណងរួមគឺ លើកកំពស់ការផ្តល់សេវាដល់គ្រប់ផ្នែកទាំងអស់នៃជំនួយ ជនរងគ្រោះ

អោយបាន ៨០%នៃអ្នករស់ រាន ពីគ្រាប់មីន និង កាកសំណល់សល់ពីសង្គ្រាម និង សហគមន៍ដែល រងផលប៉ះពាល់។ បើដូច្នោះមែន អាចមានចំនួនអ្នក រស់រាន ពីគ្រាប់មីន និង កាកសំណល់សល់ពីសង្គ្រាមរហូតដល់ ៨០ ០០០ នាក់ នេះជាគោលដៅដ៏ប្រឈមមួយ។ ហើយថេរវេលាកំណត់គឺឆ្នាំ២០១១ ហើយទិសដៅផ្សេងៗទៀត ផ្តោតលើការកសាងសមត្ថភាព ការពង្រឹងស្ថាប័ន ការបង្កើនការយល់ដឹង និង ការប្រមូលព័ត៌មាន ជាជាងការផ្តល់សេវាកម្ម[៣១]។

ដោយកង្វះសមត្ថភាព និង ហិរញ្ញវត្ថុ CNIDAH មិនមានលទ្ធភាពធ្វើប្រតិបត្តិការផែនការ និង តាមដានសកម្មភាពពាក់ព័ន្ធនានាទេ។ សកម្មភាពរបស់គេត្រូវបានកំរិតត្រឹមតែការពិភាក្សាជាមួយក្រសួងនានា និង ប្រតិបត្តិករ អំពីការមើលឃើញការអនុវត្តន៍ និង ទទួលខុសត្រូវរបស់គេ និង ការប្រជុំស្វែងរកមូលនិធិប៉ុណ្ណោះ[៣២]។ ភាពជឿនលឿនជាច្រើនពឹងអាស្រ័យលើការយល់កាន់តែច្បាស់ពីចំនួននិងតម្រូវការរបស់អ្នករស់រាន ដែលធ្វើមិនបានសម្រេចមកដល់ឆ្នាំ ២០០៩ និងការលើកកំពស់កិច្ចសម្របសម្រួល។

អនុគណកម្មការរបស់ CNIDAH ដែលរួមបញ្ចូលតំណាងនៃក្រសួងពាក់ព័ន្ធ និង ប្រតិបត្តិករក្រៅរដ្ឋាភិបាល បានត្រូវសម្របសម្រួល និង តាមដានជំនួយជនរងគ្រោះតាំងពីឆ្នាំ ២០០១ មក។ ទោះជាយ៉ាងណា នៅក្នុងឆ្នាំ ២០០៥ មានរបាយការណ៍ថា គណកម្មការមិនបានប្រជុំទៀងទាត់ទេ ហើយក្រោយមកត្រូវបានកត់សំគាល់ឃើញថា មិនបានអញ្ជើញអង្គការចូលរួមអោយជាប់លាប់ទេ ហើយអង្គការជនពិការនិងអ្នករស់រានជីវិតរិតតែបានចូលរួមកាន់តែតិចទៅទៀត[៣៣]។ វត្តមាននៃទីប្រឹក្សាអន្តរជាតិរយៈពេលខ្លី ដែលបានជំរុញការបង្កើតផែនការជំនួយជនរងគ្រោះ ដែលបាននាំអោយមានការសម្របសម្រួលស្តីពីជំនួយជនរងគ្រោះ/ពិការក្នុងឆ្នាំ២០០៦-២០០៧ ជាមួយដៃគូពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំ និងការបង្កើតក្រុមការងារតាមវិស័យបានប្រសើរឡើងមួយរយៈ។ នៅក្នុងឆ្នាំ២០០៩ CNIDAH បានទទួលស្គាល់ថា គ្មានការគាំទ្រជំនួយបច្ចេកទេសពីអន្តរជាតិ កិច្ចខំប្រឹងប្រែងទាំងនេះបានថយចុះវិញនៅក្នុងឆ្នាំ ២០០៨ ហើយថាពិតជាត្រូវការជំនួយបច្ចេកទេសរយៈពេលវែង[៣៤]។ ការរៀបចំផ្ទៃក្នុងឡើងវិញ និងការប្រឈមខាងភស្តុភារគឺជាឧបសគ្គនៅក្នុងឆ្នាំ ២០០៨។

CNIDAH ក៏បាននិយាយផងដែរថា ខ្លួនគ្មានអាណត្តិដើម្បីបញ្ជារដល់ក្រសួងផ្តល់សេវាទាំងពីរនោះទេ-ក្រសួងសុខាភិបាលនិងក្រសួងសមាហរណកម្មនិងជំនួយការសង្គម។ ការសម្របសម្រួលរវាងក្រសួងនៅខ្សោយ ហើយ ត្រូវបានរារាំងដោយគោលនយោបាយវិមជ្ឈការ ដែលអាជ្ញាធរខេត្តត្រូវសម្របសម្រួលសកម្មភាព និង លៃទុកថវិកា តែជាញឹកញាប់មិនឃើញថាជំនួយជនរងគ្រោះ/ពិការជាអាទិភាពទេ។

ចម្លើយអ្នករស់រានបញ្ជាក់អំពីការប្រឈមក្នុងការសម្របសម្រួល ដោយ ៣១%និយាយថា គេដឹងថានរណាទទួលខុស ត្រូវការសម្របសម្រួលជំនួយជនរងគ្រោះ ហើយនិយាយថា ការសម្របសម្រួលជំនួយជនរងគ្រោះបានប្រសើរឡើង។ ១១% បានគិតថា អ្នករស់រានបានចូលរួមនៅក្នុងកិច្ចប្រជុំសម្របសម្រួល ហើយ ២៣% បាន និយាយថា គេបានទទួលព័ត៌មានជាប្រចាំអំពីការសម្រេចបានជំនួយជនរងគ្រោះ។ ទោះជាយ៉ាងណា ៤៩% បានគិតថា តម្រូវការរបស់ពួកគេត្រូវបានយកទៅពិចារណា នៅពេលកំណត់ពីអាទិភាពជំនួយជនរងគ្រោះ។ នេះអាចទាក់ទងនឹងកំណើនសកម្មភាពរបស់អង្គការជនពិការ ការប៉ាន់ប្រមាណរបស់អង្គការនិងការចុះពិនិត្យដល់គំរោងជំនួយជនរងគ្រោះ

/ជនពិការនៃ CNIDAH ។ អ្នកអនុវត្តភាគច្រើន (៦០%) បានគិតផងដែរថា រដ្ឋាភិបាលមិនបានប្រកាន់យកការទទួលខុសត្រូវច្រើនឡើងទៀតចំពោះបញ្ហាជំនួយជនរងគ្រោះ/ជនពិការទេ ហើយក៏មិនបានបញ្ចូលអ្នករស់រានឬតម្រូវការរបស់គេនៅក្នុងការធ្វើផែនការផងដែរ ។ ហើយចំនួនភាគរយដូចគ្នា (៦០%) មិនបានឃើញមានការសម្របសម្រួលច្រើនឡើងនៅក្នុងចំណោមស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ឬ បានលើកកំពស់ការសម្របសម្រួលរវាងរដ្ឋាដភិបាល និង អង្គការទេ។ ចំនួន ៨០% បាននិយាយថាគ្មានភាពប្រសើរឡើងនៅក្នុងការ សម្របសម្រួលលើវិស័យពិការភាពទូលំទូលាយឬបាននឃើញថាការធ្វើផែនការបានបណ្តាលអោយមានចន្លោះប្រហោងនៅក្នុងសេវា គ្មាននរណាម្នាក់គិតថាគេបានទទួលព័តិមានជាប្រចាំអំពីការសម្រេចបានជំនួយការជនរងគ្រោះទេ។

អ្នករស់រាន ៥៤%បាននិយាយថា រដ្ឋាភិបាលខ្វះឆន្ទះនយោបាយដើម្បីលើកកំពស់ជំនួយជនរងគ្រោះ។ នេះជាការពិតនៅ លំដាប់ក្រសួង ឧទាហរណ៍ កង្វះភាពជឿនលឿនក្នុងភាពជាម្ចាស់នៅថ្នាក់ជិតលើ PNR ។ បានបញ្ជាក់ថារដ្ឋាភិបាលមាន អាទិភាពផ្សេងៗទៀត តែការប្រឈមជាចម្បងគឺកង្វះជំនួយបច្ចេកទេស។

## សេចក្តីសន្និដ្ឋាន

- វិស័យដែលអ្នករស់រានបានឃើញថា ប្រសើរខ្លាំងគឺដូចដែលបានកត់សំគាល់ដោយ CNIDAH ជាពិសេសការថែទាំដោយថ្នាំ ។ យ៉ាងណា ជារួមសេវានៅតែមានកំណត់ដដែល ជាពិសេសនៅតំបន់ជនបទ។
- ផលវិបាកអវិជ្ជមាននៃកង្វះដំណើរការរបស់ PNR សម្រាប់ស្តារនីតិសម្បទា នៅមិនទាន់មានការចាប់អារម្មណ៍ពីអ្នករស់រានទេ ដោយសារទើបតែកើតឡើងថ្មីៗ។
- ជាទូទៅអ្នកអនុវត្តបានឃើញមានភាពជឿនលឿនតិចតួចជាងអ្នករស់រានការចង្អុលបង្ហាញពីសក្តានុពលនៃការប្រឈមក្នុងការធ្វើការជាមួយអាជ្ញាធរ តែយ៉ាងហោចណាស់ក៏ប្រព័ន្ធនោះ រក្សាទុកនូវប្រតិបត្តិការសម្រាប់អ្នករស់រានដែរ។
- បើទោះជាមានកំណើនសេដ្ឋកិច្ចគួរអោយកត់សំគាល់ក្តី ក៏ក្រុមងាយរងគ្រោះជាច្រើន រួមទាំងអ្នករស់រានពីមីន និងកាកសំណល់គ្រឿងផ្ទុះល់ពីសង្គ្រាម និង ជនពិការដោយសង្គ្រាមផ្សេងទៀតមិនបានទទួលផលពីការរីកចំរើនទេ តែទំនងជាបណ្តាលឱ្យមានគំលាតខុសគ្នា និង ចន្លោះកាន់តែធំនៅក្នុងសង្គម។
- ការរើសអើងប្រឆាំងនឹងអ្នករស់រាន និង ជនពិការផ្សេងៗទៀតបានកើតមានដោយសារកង្វះច្បាប់ និង កង្វះការយល់ដឹង ដែលបណ្តាលមានឱកាសកាសការងារតិចតួច និង ការធ្វើអោយឯកោរពីសង្គមផងដែរ។
- សមត្ថភាពអង្គការជនពិការកើនឡើង តែត្រូវការអោយមានការគាំទ្រជាបន្ត ដើម្បីអោយមានប្រសិទ្ធីភាព លើការតស៊ូមតិសម្រាប់សិទ្ធិអ្នករស់រាន និង ជនពិការ។
- ការចាកចេញរបស់អង្គការ(អាចមុនអាយុកាល) បានបន្សល់ទុកនូវចន្លោះជាពិសេសនៅក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ការស្តារនីតិសម្បទា
- កង្វះខាតសមត្ថភាពនិងអាណត្តិដើម្បីសម្របសម្រួលអោយមានប្រសិទ្ធិភាពរបស់ CNIDAH ហើយក្រសួងនានាហាក់ដូចជា មិនមានភាពជាម្ចាស់ ហើយអ្នករស់រានកម្របានចូលរួម។

## ការស្នើរឡើងសម្រាប់ផែនការអនាគត

នៅពេលសួរអំពីការរំពឹងទុករបស់ពួកគេសម្រាប់ស្ថានភាពប្រាំឆ្នាំខាងមុខ ៤៩%នៃអ្នករស់រានមានអារម្មណ៍ថាវានឹងប្រសើរឡើងជាងសព្វថ្ងៃ ហើយ៣១%មានអារម្មណ៍វានឹងនៅតែដដែល រីឯ២០%ទៀតមានអារម្មណ៍ថា នឹងយ៉ាប់ជាងមុន។ ដើម្បីជួយអោយអនាគតល្អប្រសើរ គួរតែពិចារណាលើយោបល់ខាងក្រោម៖

- ដោះស្រាយជាបន្ទាន់នូវកង្វះភាពជាម្ចាស់ និង ដំណើរការមិនប្រក្រតីរបស់ PNR និង ស្តារនីតិសម្បទា វិស័យស្តារកាយសម្បទាមុនពេលដែលអ្នករស់រានដឹង។
- បង្កើតឱកាសសមាហរណកម្មសេដ្ឋកិច្ចសម្រាប់អ្នករស់រានពីមីន និងកាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម និងជនពិការដោយ សារសង្គ្រាមទាំងអស់រួមទាំងអនុវត្តប្រព័ន្ធការងារកូតា ហើយបង្កើនការតាមដានលើការយកពួកគេឱ្យធ្វើការងារ
- ធានាបង្កើតអោយមានភាពវិជ្ជមាននៃការផ្តល់សេវាដែលមាននៅទីក្រុងបានពង្រីកទៅដល់ជនបទផងដែរ
- ធានាថាស្ថាប័នជំនួយជនរងគ្រោះ/ពិការមានអាណត្តិនិងសមត្ថភាពគ្រប់គ្រាន់ដើម្បីសម្របសម្រួលលើវិស័យដែលមានស្រាប់ក្នុងរយៈពេលខ្លី ការផ្តល់ជំនួយបច្ចេកទេសដល់ CNIDAH និង ការបញ្ជាក់អំពីតួនាទីរបស់ខ្លួន និងក្រសួងនានាហើយក្នុងរយៈពេលមធ្យមឬរយៈពេលវែងត្រូវមានយន្តការរួមួយសម្របសម្រួលជនពិការ
- អនុមតិច្បាប់ជនពិការដ៏ទូលំទូលាយមួយ បង្កើតផែនការពិការភាពដ៏ទូលំទូលាយមួយ ហើយបង្កើតស្ថាប័នដើម្បីសម្របសម្រួល និង តាមដានការអនុវត្តន៍។
- សមាហរណកម្មជំនួយជនរងគ្រោះ (និងផែនការឆ្នាំ ២០០-២០១១) ផ្តោតលើបញ្ហាពិការភាពច្រើនឡើង ហើយធានាថា ក្រសួងពាក់ពន្ធមើលឃើញការជួយអ្នករស់រានពីមីន និង កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមថាជាផ្នែកមួយនៃអាណត្តិរបស់ខ្លួន។
- រួមបញ្ចូលជាប្រព័ន្ធនូវអ្នករស់រាន និង ជនពិការក្នុងការសម្របសម្រួលជំនួយជនរងគ្រោះ/ជនពិការអនុវត្ត និង តាមដាន ហើយនឹងលើកកំពស់ទំនាក់ទំនងជាមួអង្គការ។
- បន្តកសាងសមត្ថភាពអង្គការជនពិការ ជាពិសេសដើម្បីពង្រីកក្រុមគោលដៅរបស់គេនិងរួមបញ្ចូលសកម្មភាពគាំទ្រផ្លូវចិត្តនៅក្នុងការងាររបស់គេ

**តើអ្នកគិតថា ស្ថានភាពរបស់អ្នកនឹងក្លាយទៅជាយ៉ាងណានៅក្នុងប្រាំឆ្នាំទៀត?**



### សម្ព័ន្ធជនរងគ្រោះផ្ទាល់....

អាទិភាពនៃជំនួយជនរងគ្រោះក្នុងប្រាំឆ្នាំខាងមុខគឺ:

- ភាពប្រសើរឡើងនៃការអនុវត្តច្បាប់
- ការហ្វឹកហ្វឺនអំពីការងារ
- ភាពប្រសើរឡើងនៃបរិក្ខា និង ការហ្វឹកហ្វឺនអំពីអ្នកបច្ចេកទេសធ្វើ និង ដាក់សរីរាង្គកាយ
- ការបង្កើតឱកាសការងារ និង ការដកយកចេញនូវឧបសគ្គ
- ការហ្វឹកហ្វឺននៅតាមជនបទ និង បង្កើតលក្ខខណ្ឌដោយរួមបញ្ចូលអ្នកពិការក្មេងផងដែរ ។
- ធ្វើឱ្យយ៉ាងរឹងមាំ ។ ខ្ញុំមិនដឹងច្បាស់!
- ផ្តល់លទ្ធភាពទទួលបានយន្តការសមាហរណកម្មសេដ្ឋកិច្ចច្បាស់លាស់ ព្រោះថាបើអ្នកបានឱកាសនេះអ្នកនឹងអាចធ្វើការងារមានប្រយោជន៍ផ្សេងៗ ។
- សមាហរណកម្មអ្នករស់រានទាំងអស់មិនមែនតែទីផ្សារការងារទេ
- សមាហរណកម្មអ្នករស់រានទាំងអស់ទៅក្នុងសង្គម ទាំងមូល ។

### សម្ព័ន្ធជនរងគ្រោះផ្ទាល់....

ប្រសិនបើប្រទេសពិតជាយកចិត្តទុកដាក់ដល់អ្នករស់រានមែនគេគួរតែ:

- ធ្វើសមាហរណកម្មសេដ្ឋកិច្ចខ្លាំងឡើងដោយមិនទុកអោយអ្នករស់រានពឹងផ្អែកតែលើការបរិច្ចាកនោះទេ ។
- ជួយជនពិការអោយបានច្រើនឡើង និង ញឹកញាប់ ។
- គេមិនត្រូវមិនយកចិត្តទុកដាក់ទេ ។
- បង្កើនការយល់ដឹង និង ការគាំទ្រផ្លូវចិត្តច្រើនឡើង ។
- បង្កើតស្ថាប័នមួយសម្របសម្រួលសកម្មភាពពិការភាពនៃប្រតិបត្តិករទាំងអស់ ។
- ផ្តល់ឱកាសអោយជនពិការគ្រប់ប្រភេទ ។
- អនុម័តច្បាប់ និង ក្នុងករណី អង់កូឡា អង្កេតតាមដាន និងជំរុញការអនុវត្តច្បាប់ជួលជនពិការឱ្យធ្វើការងារ ។
- បង្កើតស្ថាប័នប្រតិបត្តិសមាហរណកម្មទូលំទូលាយមួយ ។
- ផ្តល់ឱកាសការងារច្រើនថែមទៀត ។
- អនុម័តគោលនយោបាយជាក់លាក់សម្រាប់ស្តារនិងសមាហរណកម្មសេដ្ឋកិច្ច ។

### សម្ព័ន្ធជនរងគ្រោះផ្ទាល់....
### បទពិសោធន៍ជីវិតរបស់នាង ប៉ាលមីរា វ៉ាន់ណាឡា

ប៉ាលមីរាមានអាយុ៣៧ឆ្នាំ បានជាន់មីនពេលនាងត្រឡប់មកពីសាលាហើយបាត់បង់ជើងស្តាំ នៅពេលនាងមានអាយុ៨ឆ្នាំ។ នាងរស់នៅជាមួយឪពុកមានៅខាលឡា (៣០គ.ម ពីហួមបូ) ដោយសារឪពុកម្តាយនាងបានបាត់ខ្លួន។ ពេលនាងមានវ័យជំទង់គ្រួសារក៏វិលមកនៅ ហួមបូ ដូចនេះ ជាលើកដំបូងហើយដែលនាងបានជើងសិប្បនិមិត្ត ហើយបន្តការសិក្សារបស់នាង។ នៅអាយុ២៧ឆ្នាំ នាងជួបបុរសម្នាក់ហើយមានផ្ទៃពោះ តែបុរសនោះមិនចង់បានប្រពន្ធពិការទេ ហើយឪពុកមានាងក៏ដេញនាងចេញពីផ្ទះដែរ។ ព្រោះបុរសនោះបានស្លាប់ភ្លាមៗក្រោយមកគ្រួសាររបស់នាងចោទនាងថាជាស្រីធ្មប់។

ដោយត្រូវបោះបង់និងនៅតែឯងនាងត្រូវរកមធ្យោបាយដើម្បីរស់ ពេលនោះនាងក៏ចាប់ផ្តើមលក់ស្រា។ ជំនួញតូចរបស់នាងបានរីកចម្រើនយ៉ាងរហ័ស។ តែមកដល់ឥឡូវនេះ នាងមានកូនបីហើយដែលត្រូវមើលនិងថែទាំដោយខ្លួនឯង ហើយចំណូលរបស់នាង មិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមកូនរាល់ថ្ងៃនោះទេ។ អរគុណដល់អង្គការអន្តរជាតិដែលនាងត្រូវបាន ជ្រើសរើសអោយចូលរួមនៅក្នុងគំរោងសួនដំណាំរកប្រាក់ចំណូលនៅក្នុងក្រុងហួមបូ។ នាងធ្វើការនៅទីនោះពេលព្រឹក ហើយគ្រប់គ្រងហាងនាងក្រោយពីការងារ។ ដោយមានការងារទ្វេរនេះ នាង នឹងអាចមានលទ្ធភាពបំពេញនូវតម្រូវការកូនរបស់នាង ហើយប្រហែលជានាងអាចទិញបានដីមួយដុំ សម្រាប់សង់ផ្ទះផងដែរ។ តែជាបឋមនិងសំខាន់បំផុត នាងចង់រកលុយឱ្យបានគ្រប់គ្រាន់ដើម្បីបញ្ជូនកូនរបស់នាងទៅសាលា។

# Angola

[1] ICBL, *Landmine Monitor Report 2008*, October 2008, Ottawa, pp. 131-132; and ICBL, *Landmine Monitor Report 2004*, Washington, DC, October 2004, p. 121.

[2] ICBL, *Landmine Monitor Report 2008*, October 2008, Ottawa, pp. 131-132

[3] [3]UNDP, "2008 Statistical Update - Angola," http://hdrstats.undp.org/en/countries/data_sheets/cty_ds_AGO.html, accessed 23 July 2009; and UNDP, *Human Development Report 2004: Cultural Liberty in Today's Diverse World*, New York, 2004, p. 142.

[4] UNDP, "2008 Statistical Update - Angola," http://hdrstats.undp.org/en/countries/data_sheets/cty_ds_AGO.html, accessed 23 July 2009; and UNDP, *Human Development Report 2004: Cultural Liberty in Today's Diverse World*, New York, 2004, p. 142.

[4]World Bank, "Gross national income per capita 2008, Atlas method and PPP," 1 July 2009, http://siteresources.worldbank.org/DATASTATISTICS/Resources/GNIPC.pdf; UN Statistics Division, "Per capita GNI at current prices – US Dollars," http://data.un.org/Data.aspx?d=SNAAMA&f=grID%3A103%3BcurrID%3AUSD%3BpcFlag%3A1, accessed 23 July 2009

[5] CIA, *The World Factbook – Angola*, https://www.cia.gov/library/publications/the-world-factbook/geos/ao.html; and 2004, http://www.umsl.edu/services/govdocs/wofact2004/geos/ao.html, accessed 23 July 2009.

[6] WHO, "Detailed Database Search, Angola," http://apps.who.int/whosis/data/Search.jsp?indicators=%5bIndicator%5d.%5bHSR%5d.Members, accessed 23 July 2009.

[7] WHO, "World Health Statistics 2009," Geneva, 2009, pp. 95-96. The WHO estimates that countries with less than 23 healthcare professionals (physicians, nurses and midwives) per 10,000 population will be unlikely to achieve adequate coverage.

[8] UN, "Convention [on the Rights of Persons with Disabilities] & Optional Protocol Signatories & Ratification," http://www.un.org/disabilities/countries.asp?id=166, as accessed on 1 August 2009, delays in updating the webpage were noted.

[9] UNDP, "2008 Statistical Update - Angola," http://hdrstats.undp.org/en/countries/data_sheets/cty_ds_AGO.html; and CIA, *The World Factbook – Angola*, https://www.cia.gov/library/publications/the-world-factbook/geos/ao.html, accessed 23 July 2009.

[10] ICBL, *Landmine Monitor Report 2007*, October 2007, Ottawa, p. 153.

[11] [11]Statement of Angola, Nairobi Summit on a Mine-Free World, Nairobi, 3 December 2004.

[12] See Angola chapters in *Landmine Monitor Reports*, 1999-2008; "Final Report of the Sixth Meeting of States Parties/Zagreb Progress Report,"Part II, Annex V, Zagreb, 28 November-2 December 2005, pp. 106-111; and CNIDAH, "Revised 2005-2009 objectives," November 2007,provided by email from Anna Kudarewska, Landmine Monitor Researcher, 9 May 2008.

[13] 13 In total, 41 questionnaires were received but only 35 were complete enough for analysis and/or fitted survey criteria.

[14] 14 Survey Action Center, "Landmine Impact Survey, Republic of Angola, Final Report," Washington, DC, November 2007, pp. 9, 13, and 35-39.

[15] 15 ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, pp. 142-143; email from Pedro Ribeiro, Info Systems National Advisor, UNDP/CNIDAH, 19 June 2009; and interview with Madalena Neto, VA Coordinator, CNIDAH, Geneva, 28 May 2009

[16] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 147; CNIDAH, "Revised 2005-2009 objectives," November 2007; and interview with Madalena Neto, VA Coordinator, CNIDAH, Geneva, 28 May 2009.

[17] Email from Raul Feio, Health Expert, European Commission (EC) Delegation in Angola, Luanda, 29 June 2009.

[18] 14% non-response rate.

[19] See *Landmine Monitor Report* 2008, pp. 147-148; ICBL, *Landmine Monitor Report 2007*, Ottawa, October 2007, p. 158; Anders Eklund, "Evaluation of Five Physical Rehabilitation Centers in Angola," Luanda, September 2005, p. 2; and email from Claude-Alain Amiet, Orthopedic Technical Advisor, Ministry of Health/GTZ, 18 June 2009.

[20] Statement of Angola, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009; and interview with Madalena Neto, VA Coordinator, CNIDAH, Geneva, 28 May 2009

[21] "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 109; and statement of Angola, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009; and CNIDAH, "Revised 2005-2009 objectives," November 2007

[22] The remainder did not answer or was not sure.

[23] 11% non-response rate.

[24] ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 152.

[25] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 148; ICBL, *Landmine Monitor Report 2006*, Ottawa, July 2006, p. 180; and "Revised 2005-2009 objectives," November 2007.

[26] ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p. 148.

[27] ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 153.

[28] Statement of Angola, Nairobi Summit on a Mine-Free World, Nairobi, 3 December 2004.

[29] Angola, Article 7 Report, Form J, 14 September 2004

[30] Two sets of objectives exist, one in the "Mid-Term Review of the Status of VA in the 24 Relevant States Parties," Geneva, 21 November 2007, pp. 19-21; and more detailed objectives in CNIDAH, "Revised 2005-2009 objectives," November 2007

[31]CNIDAH, "Revised 2005-2009 objectives," November 2007.

[32] CNIDAH, "Report on the Activities carried out by the Sub-Commission on Assistance and Social Reintegration during the First Semester of 2008," Luanda, 18 July 2008; and "Report on the Activities carried out by the Sub-Commission on Assistance and Social Reintegration during the Second Semester of 2008," Luanda, 2009.

[33] ICBL, *Landmine Monitor Report 2005*, Ottawa, October 2005, p. 148; and ICBL, *Landmine Monitor Report 2008*, Ottawa, October 2008, p.149.

[34] Interview with Madalena Neto, VA Coordinator, CNIDAH, Geneva, 28 May 2009